

ដោយប្រធាន រ័សុល អិម ណិលសុន

# អំណាចនៃព្រះវិហារបរិសុទ្ធ

នៅខែ មិនា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយបានទិញព្រះវិហារបរិសុទ្ធខឺតឡង់ ។ ព្រះវិហារបរិសុទ្ធនេះគឺជាផ្នែកដ៏សំខាន់នៃការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ ព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះអង្គទ្រង់ដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរ នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ។ ព្រះអង្គសង្គ្រោះបានទទួលយកព្រះវិហារបរិសុទ្ធជាព្រះដំណាក់របស់ទ្រង់ ។ បន្ទាប់មកទ្រង់បានសន្យាថា « យើងនឹង **សម្ដែងកាយ** យើងដល់រាស្ត្ររបស់យើងនៅក្នុងដំណាក់នេះដោយសេចក្ដីមេត្តាករុណា » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១១០:៧ ) ។ ការសន្យានេះអនុវត្តចំពោះគ្រប់ព្រះវិហារបរិសុទ្ធនៅសព្វថ្ងៃនេះ ។

នៅក្នុងព្រះវិហារបរិសុទ្ធ ប្អូនៗអាចទទួលចម្លើយចំពោះការអធិស្ឋាន ។ ប្អូនៗក៏អាចទទួលបានសេចក្ដីជំនឿ កម្លាំង ការលួងលោម ចំណេះដឹង និងអំណាចផងដែរ ។ ពេលវេលានៅក្នុងព្រះវិហារបរិសុទ្ធនឹងជួយប្អូនៗឲ្យគិតដល់សេឡេស្ទាល ហើយមើលឃើញថាខ្លួនប្អូនៗជានរណាពិតប្រាកដ ហើយតើប្អូនៗអាចក្លាយជាបុគ្គលបែបណា ។ វានឹងជួយប្អូនៗឲ្យយល់អំពីរបៀបដែលប្អូនៗរួមចំណែកនៅក្នុងផែនការដ៏អស្ចារ្យរបស់ព្រះ ។ ខ្ញុំសូមសន្យានឹងប្អូនៗដូច្នោះ ។ ●



« ព្រះវិហារបរិសុទ្ធ គឺជាច្រកទ្វារនាំទៅកាន់ពរជ័យដ៏មហិមាបំផុតដែលព្រះមានសម្រាប់យើងម្នាក់ៗ ។

ប្រធាន រ័សុល អិម ណិលសុន

**សម្ដែងកាយ ៖** បង្ហាញ ឬ ធ្វើឲ្យដឹង



*កែសម្រួលមកពី « រីករាយនៅក្នុងអំណោយទាននៃកូនសោបព្វជិតភាព »* Liahona *ខែ ឧសភា ឆ្នាំ ២០២៤ ទំព័រ ១១៩–១២១ ។*

## សកម្មភាពកាត់ក្រដាស

កាត់ជុំវិញតែមព្រះវិហារបរិសុទ្ធខឺតឡង់ ។ បន្ទាប់មកបត់លើបន្ទាត់ចុចៗ ហើយបិតផ្នែកខាងៗ និងដំបូលឲ្យជាប់គ្នា ។




## តើព្រះវិហារបរិសុទ្ធខឺតឡង់ គឺជាអ្វី ?



ព្រះវិហារបរិសុទ្ធខឺតឡង់ ត្រូវបានកសាងឡើងនៅក្នុងរដ្ឋអូហៃអូ សហរដ្ឋអាមេរិក នៅឆ្នាំ ១៨៣៦ ។ វាគឺជាព្រះវិហារបរិសុទ្ធដំបូងគេបង្អស់នៃសាសនាចក្រដែលបានស្ដារឡើងវិញ ។

ទីក្រុងខឺតឡង់ រដ្ឋអូហៃអូ

ក្រោយមក សមាជិកសាសនាចក្របានចាកចោលព្រះវិហារបរិសុទ្ធនេះដើម្បីផ្លាស់ទីទៅភាគខាងលិច ។ ព្រះវិហារមួយផ្សេងទៀតបានកាន់កាប់អគារនេះអស់ជាច្រើនឆ្នាំ ។ ថ្មីៗនេះ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយបានទិញព្រះវិហារបរិសុទ្ធនេះ ។